ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារសម្រេចបានឆ្នាំ២០២៤ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ




ធានាសមធម៌និងសាមគ្គីធម៌សង្គម និងលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋ

# បេឡាជាតិសន្តិសុខសង្គម

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារសម្រេចបានឆ្នាំ២០២៤
## និងទិសដៅអនុវត្តបន្តឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គម
## នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ប.ស.ស.
ហានិភ័យការងារ

ប.ស.ស.
ថែទាំសុខភាព

ប.ស.ស.
ប្រាក់សោធន

ប.ស.ស.
និកម្មភាពការងារ

# មាតិកា

**បុព្វកថា** ........ I
**សេចក្តីសង្ខេប** ........ II
**ចក្ខុវិស័យ** ........ III
**អង្គភាពប្រតិបត្តិបេឡាជាតិសន្តិសុខសង្គម** ........ IV
**១. សេចក្តីផ្តើម** ........ ១
**២. លទ្ធផលការងារសម្រេចបាន** ........ ២
**ក. ការពង្រឹង និងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម** ........ ៣
ក.១. ការចុះបញ្ជិកាក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថាន និងសមាជិក ........ ៣
ក.២. បច្ចុប្បន្នភាពក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថាន និងសមាជិក ........ ៤
ក.៣. ការចុះអធិការកិច្ចបញ្ជិកា ........ ៦
ក.៤. ការកសាងលិខិតបទដ្ឋាននៃការអនុវត្តរបបសន្តិសុខសង្គម ........ ៦
**ខ. ការពង្រឹង និងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម** ........ ៧
ខ.១. ការពង្រឹងសេវាទូទាត់ និងបើកផ្តល់តាវកាលិករបបសន្តិសុខសង្គម ........ ៧
ខ.២. ការពង្រឹង និងបង្កើនគុណភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាល ........ ៨
**គ. ការលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម** ........ ៩
គ.១. ការពង្រឹងសេវាផ្តល់ព័ត៌មានអតិថិជន និងដោះស្រាយបណ្តឹង ........ ៩
គ.២. ការសហការបង្កើនការផ្សព្វផ្សាយ អប់រំ និងបង្ការ ........ ១០
គ.៣. ការវាយតម្លៃការយល់ដឹង និងភាពពេញចិត្ត ........ ១៣
**ឃ. ការពង្រឹងការគ្រប់គ្រង និងចាត់ចែងមូលនិធិសន្តិសុខសង្គម** ........ ១៣
ឃ.១.ពង្រឹងការបង់ភាគទានតាមរយៈការត្រួតពិនិត្យតាមដាន និងចាត់វិធានការ ........ ១៣
ឃ.២.ការវាយតម្លៃស្ថានភាពហានិភ័យហិរញ្ញវត្ថុសន្តិសុខសង្គម ........ ១៦
**ង. ការអភិវឌ្ឍសមត្ថភាពបេឡាជាតិសន្តិសុខសង្គម** ........ ១៦
ង.១. ការអភិវឌ្ឍធនធានមនុស្ស ........ ១៦
ង.២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ........ ១៧
ង.៣. ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ........ ១៧
ង.៤. ប្រព័ន្ធប្រតិបត្តិការ និងសន្តិសុខបច្ចេកវិទ្យា ........ ១៩
ង.៥. ការងារគាំទ្រទូទៅ ........ ២០

**ច. ការអនុវត្តកម្មវិធីជំនួយសង្គម** ........ ២២
ច.១. កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក **ប.ស.ស.** ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ........ ២២
ច.២. ការចុះបញ្ជី និងផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល ........ ២៣
**៣. បញ្ហាប្រឈមចម្បងៗ** ........ ២៣
**៤. ទិសដៅអនុវត្តការងារបន្ត** ........ ២៣
**៥. សេចក្តីសន្និដ្ឋាន** ........ ២៤
**៦. ឧបសម្ព័ន្ធ** ........ ២៥

# បុព្វកថា

ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយជាអនេក សូមផ្សព្វផ្សាយនូវសៀវភៅរបាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០២៤ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនដល់ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា និងអង្គភាពក្រោមឱវាទ **ប.ស.ស.**។ សៀវភៅនេះ គឺជាឯកសារបង្ហាញពីសមិទ្ធផលនៃការអនុវត្តរបបសន្តិសុខសង្គមក្នុងរយៈពេលពេញមួយឆ្នាំ២០២៤ ដែលផលិតដោយនាយកដ្ឋានគោលនយោបាយសន្តិសុខសង្គមនៃ **ប.ស.ស.** និងបានផ្តល់នូវទស្សនាទានយ៉ាងទូលំទូលាយលើការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន និងការចូលរួមអនុវត្តកម្មវិធីជំនួយសង្គមរបស់រាជរដ្ឋាភិបាល តាមរយៈការពង្រឹងនិងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម ការពង្រឹងនិងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម ការលើកកម្ពស់ការយល់ដឹងនិងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម ការពង្រឹងការគ្រប់គ្រងនិងចាត់ចែងមូលនិធិសន្តិសុខសង្គម និងការអភិវឌ្ឍសមត្ថភាពបេឡាជាតិសន្តិសុខសង្គម ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រទី៥ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ ក្រោមការចង្អុលបង្ហាញរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណដល់ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់អនុសាសន៍ណែនាំជាបន្តបន្ទាប់រហូតទទួលបានផ្លែផ្កាគួរជាទីមោទនៈ និងថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកនៃ **ប.ស.ស.** ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងភាគីពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍តែងតែផ្តល់ការសហការគាំទ្រដល់ **ប.ស.ស.** រហូតដល់សម្រេចបានលទ្ធផលការងារដូចមាននៅក្នុងសៀវភៅរបាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០២៤ និងទិសដៅអនុវត្តបន្តឆ្នាំ២០២៥។

ថ្ងៃពុធ ១៣កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មីនា ឆ្នាំ២០២៥

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**អគ្គនាយកបេឡាជាតិសន្តិសុខសង្គម**

**ម៉េង ហុង**

# សេចក្ដីសង្ខេប

របបសន្តិសុខសង្គមនៅព្រះរាជាណាចក្រកម្ពុជា គឺស្ថិតនៅក្រោមការចាត់ចែង និងគ្រប់គ្រងរបស់ **ប.ស.ស**. ហើយបានបោះជំហានទៅមុខប្រកបដោយវឌ្ឍនភាព ចាប់ពីការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិតនៅឆ្នាំ២០០៨ និងសម្រាប់មន្ត្រីសាធារណៈនៅឆ្នាំ២០២១ ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតនៅឆ្នាំ២០១៦ និងសម្រាប់មន្ត្រីសាធារណៈនៅឆ្នាំ២០១៨ និងផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក **ប.ស.ស**. នៅចុងឆ្នាំ២០២៣ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិតនៅឆ្នាំ២០២២។ លើសពីនេះ ដោយមានការទុកចិត្តពីរាជរដ្ឋាភិបាលបានឱ្យ **ប.ស.ស**. ចូលរួមអនុវត្តបន្ថែមនៅក្នុងប្រព័ន្ធជំនួយសង្គម ដែលក្នុងនោះបានអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដែលជាសមាជិក **ប.ស.ស**. (របបភាគទានជាកាតព្វកិច្ច) ចាប់ពីខែសីហា ឆ្នាំ២០២៣ ដើម្បីជំនួសនិងបំពេញបន្ថែមនៃការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០១៨ មក និងកម្មវិធីថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធចាប់ពីឆ្នាំ២០១៨។

បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស**.) មានសមាជិកបច្ចុប្បន្នសរុប ២ ៧១៥ ០៨៤នាក់ (ស្រី ១ ៥០៣ ៩០៧នាក់) និងមានមូលដ្ឋានសុខាភិបាល (សាធារណៈ និងឯកជន) ដៃគូសរុបចំនួន ១ ៥៩៥ នៅទូទាំង ២៥រាជធានី-ខេត្ត រង់ចាំការផ្តល់សេវាជូនពួកគាត់។ **ប.ស.ស**. មានស្នាក់ការកណ្តាល និងសាខាចំនួន ៣៨ទីតាំង នៅទូទាំងប្រទេសសម្រាប់ប្រតិបត្តិការងារ និងបម្រើសេវាកម្មផ្ទាល់ជូនដល់សាធារណជនជារៀងរាល់ថ្ងៃ ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃអាទិត្យ និងពីម៉ោង ៨:៣០នាទី ដល់ម៉ោង ១៧:៣០នាទី លើកលែងស្នាក់ការកណ្តាល ដែលបម្រើសេវាកម្មផ្ទាល់ចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ២២:០០នាទី រួមមានការចុះបញ្ជីសហគ្រាសនិងសមាជិក ការទទួលការបង់ភាគទាន ការទទួលសំណើសុំទូទាត់តាវកាលិកនិងថ្លៃសេវាព្យាបាល និងការទទួលដោះស្រាយពាក្យបណ្តឹងតវ៉ាផ្សេងៗ។ ជាមួយគ្នានេះ **ប.ស.ស**. ក៏បានអភិវឌ្ឍន៍កម្មវិធីនិងប្រព័ន្ធរួមមាន NSSF Member App, Web Based Application, Tracking System និង Agent App ដើម្បីជួយសម្រួលដល់សមាជិក ក៏ដូចជាសហគ្រាសក្នុងការចុះបញ្ជី បង់ភាគទាន ទាមទារតាវកាលិក និងការបកស្រាយ ឆ្លើយតបរាល់បណ្តឹងនិងចម្ងល់។

លើសពីនេះ **ប.ស.ស**. ក៏មានបម្រើសេវាអតិថិជនពេញ ២៤ម៉ោង លើ ៧ថ្ងៃ តាមរយៈបណ្តាញទូរសព្ទឥតគិតថ្លៃលេខ ១២៨៦ និង ១២៩៧ សម្រាប់ទទួលការហៅចូលដើម្បីសាកសួរព័ត៌មានអំពីរបបសន្តិសុខសង្គម ការឆ្លើយតបនូវសំណួររបស់សាធារណជន រួមទាំងទទួលបណ្តឹងតវ៉ាផ្សេងៗផងដែរ។ **ប.ស.ស**. ក៏មានបណ្តាញសង្គមនានាដូចជា Website, Facebook, Telegram, Tiktok, X-Twitter និង Youtube សម្រាប់ផ្សព្វផ្សាយអំពីប្រតិបត្តិការនៃការអនុវត្តរបបសន្តិសុខសង្គម និងការផ្តល់នូវព័ត៌មានថ្មីៗអំពីវឌ្ឍនភាពរបស់ **ប.ស.ស**.។

# ចក្ខុវិស័យ

ដើម្បីធានាសមធម៌និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋ។

# បេសកកម្ម

ផ្តល់សេវារបបសន្តិសុខសង្គមគ្រប់ផ្នែក ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងសង្គតិភាព ដល់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលស្វ័យនិយោជន៍ព្រមទាំងអ្នកក្នុងបន្ទុក។

# គោលដៅ

ដើម្បីគ្រប់គ្រងរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន៖

ក. ការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

ខ. ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

គ. ការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

ឃ. សិក្សាសមិទ្ធលទ្ធភាពរៀបចំរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ។

# អង្គភាពប្រតិបត្តិបេឡាជាតិសន្តិសុខសង្គម



**បេឡាជាតិសន្តិសុខសង្គម**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០២៤
# និងទិសដៅអនុវត្តបន្តឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គម
# នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការរបបសន្តិសុខសង្គម ជាដំណាក់កាលទៅតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច។ នៅឆ្នាំ២០០២ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវបានអនុម័ត ហើយរបបសន្តិសុខសង្គមត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅឆ្នាំ២០០៨។ ច្បាប់នេះមានវិសាលភាពគ្របដណ្តប់មិនទាន់ទូលំទូលាយ និងមិនទាន់មានសង្គតិភាពនៅឡើយទេ ដូច្នេះក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលក៏បានបង្កើតច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី ដែលមានវិសាលភាពអនុវត្តចំពោះបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលស្វ័យនិយោជន៍។ តាមរយៈច្បាប់ថ្មីនេះរបបសន្តិសុខសង្គមត្រូវបានបែងចែកជា ៤ផ្នែករួមមាន ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ ដែលកំពុងអនុវត្តស្របតាមយុទ្ធសាស្ត្រទី៥ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ជាក់ស្តែង កម្ពុជាបានផ្លាស់ប្តូរនិងកែប្រែមុខមាត់ឡើងវិញពីប្រទេសដែលជួបនូវភ្នក់ភ្លើងសង្គ្រាម ការបែកបាក់ វេទុក្ខវេទនា ភាពក្រីក្រ ភាពអត់ឃ្លាន ភាពទន់ខ្សោយផ្នែកសង្គម-សេដ្ឋកិច្ច ទៅជាប្រទេសដែលទទួលបានភាពជោគជ័យក្នុងផ្នែកនយោបាយនិងការទូត ផ្នែកសង្គម-សេដ្ឋកិច្ច ព្រមទាំងការអភិវឌ្ឍស្ថាប័ននិងអភិបាលកិច្ចជាដើម។ ជាងនេះទៅទៀត កម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់លឿនក្នុងតំបន់និងសកលជាមួយនឹងអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមជាង ៧% ក្នុងមួយឆ្នាំរយៈពេលប្រមាណ ២ទសវត្សចុងក្រោយ មុនវិបត្តិនៃជំងឺកូវីដ-១៩ ជាមួយនឹងការរីកចម្រើនឥតឈប់ឈរនៃជីវភាពរស់នៅរបស់ប្រជាជន និងបានចាកចេញពីប្រទេសដែលមានចំណូលទាប មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ព្រមទាំងបានកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់។ ជាមួយគ្នានេះ ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩

ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាបានបង្ហាញនូវសមត្ថភាពរបស់ខ្លួនក្នុងការដោះស្រាយនូវរាល់បញ្ហាប្រឈមប្រកបដោយប្រសិទ្ធភាព និងបានទាន់ពេលវេលា ហើយត្រូវបានចាត់ទុកជាប្រទេសឈានមុខមួយក្នុងការគ្រប់គ្រងវិបត្តិនៃជំងឺកូវីដ-១៩ បានយ៉ាងល្អ ព្រមទាំងបានស្តារសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់រហ័សពីវិបត្តិនេះ។

នៅក្នុងឆ្នាំ២០២៤ នេះ បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តខិតខំបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងគោលដៅពង្រឹង ពង្រីក និងធានាឱ្យបាននិរន្តរភាពនៃការអនុវត្តរបបសន្តិសុខសង្គមគ្រប់ផ្នែក ដែលសមិទ្ធផលសំខាន់ៗទាំងនោះរួមមាន ការពង្រីកវិសាលភាពរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្ថិតក្នុងវិស័យសាធារណៈ ការពង្រីកវិសាលភាពរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់និស្សិតនគរបាលនិងសិស្សនគរបាល ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**. និងក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស**. ត្រូវបានបង្កើត ព្រមទាំងបានធ្វើការកែសម្រួលប្រតិបត្តិការរបស់ខ្លួនបន្ថែមទាំងប្រតិបត្តិការផ្ទាល់ និងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បានរៀបចំ និងបញ្ចប់របាយការណ៍នៃការយល់ដឹង និងការពេញចិត្តការអនុវត្តរបបសន្តិសុខសង្គមរបស់សមាជិក បានរៀបចំ និងបញ្ចប់របាយការណ៍វាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងបន្តធ្វើការសិក្សាវាយតម្លៃហានិភ័យហិរញ្ញវត្ថុតាមផ្នែក និងក្រុមគោលដៅនៃរបបសន្តិសុខសង្គម។ **ប.ស.ស**. ជាតួអង្គយ៉ាងសំខាន់ដែលបានចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ កម្មវិធីនយោបាយ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងគោលនយោបាយ ក្របខណ្ឌ ផែនការយុទ្ធសាស្ត្រ និងផែនការរបស់ក្រសួង ស្ថាប័ននានាសរុបប្រមាណ ២០។

## ២. លទ្ធផលការងារសម្រេចបាន

ក្នុងឆ្នាំ២០២៤ នេះ ក្រសួង ស្ថាប័ន សហគ្រាស និងគ្រឹះស្ថានកំពុងដំណើរការសរុប ២៥ ១៦៤ ស្ថាប័ន/សហគ្រាស មានសមាជិកសរុប ២ ៧១៥ ០៨៤នាក់ (ស្រី ១ ៥០៣ ៩០៧នាក់) និងទទួលបានចំណូលភាគទានសរុប ១ ៥៨៣ ៦៣១,៧៨លានរៀល ចំណាយថវិកាទូទាត់សេវាមូលដ្ឋានសុខាភិបាល និងបើកផ្តល់តាវកាលិកសរុប ៦៨១ ៨២៣,៩៦លានរៀល សមាជិកទទួលតាវកាលិកសរុប ៩៣ ៧៣៤នាក់ (ស្រី ៨០ ២៤៦នាក់) និងសមាជិកចូលប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាលសរុប ៧ ៧៩២ ៤៧៦ដង (ស្រី ៥ ៧៤៥ ៧១៦ដង)។ ជាមួយគ្នានេះដែរ **ប.ស.ស**. បានចុះបញ្ជី និងផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលដល់សមាជិកចំនួន ១៣៥ ០០២នាក់ (ស្រី ៧៤ ៥០៩នាក់) និងបានផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមជូនសមាជិក **ប.ស.ស**. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដែលមានម្តាយចំនួន ១២៤ ៨១២នាក់ និងកូនចំនួន ១២៣ ៦៦៣នាក់ ដោយចំណាយអស់ទឹកប្រាក់ប្រមាណ ១០៦ ៤០១,៣៦លានរៀល។

- **ផ្នែកហានិភ័យការងារ**

ក្រសួង ស្ថាប័ន សហគ្រាស និងគ្រឹះស្ថានកំពុងដំណើរការក្នុងឆ្នាំ២០២៤ នេះ សរុប ២៥ ១៦០ ស្ថាប័ន/សហគ្រាស មានសមាជិកចំនួន ១ ៨៣៥ ៥៧៣នាក់ (ស្រី ១ ១០៧ ៧១៩នាក់) និងទទួលបានចំណូលភាគទានសរុប ១៦៤ ៩៧៧,២៥លានរៀល ចំណាយថវិកាទូទាត់សេវាមូលដ្ឋានសុខាភិបាល និងបើកផ្តល់

តាវកាលិកសរុប ៣០ ៥៦៥,៤២លានរៀល សមាជិកទទួលតាវកាលិកសរុប ១០ ៧៦៨នាក់ (ស្រី ៥ ២២២នាក់) និងមានសមាជិកចូលប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាលសរុប ១៨ ៦៧៧ដង (ស្រី ៩ ៣៩៧ដង)។

❖ **ផ្នែកថែទាំសុខភាព**

ក្រសួង ស្ថាប័ន សហគ្រាស និងគ្រឹះស្ថានកំពុងដំណើរការក្នុងឆ្នាំ២០២៤ នេះ សរុប ២៥ ១៦៤ ស្ថាប័ន/សហគ្រាស មានសមាជិកចំនួន ២ ៧១៥ ០៨៤នាក់ (ស្រី ១ ៥០៣ ៩០៧នាក់) និងទទួលបានចំណូលភាគទានសរុប ៦២៨ ៤៩០,៤៨លានរៀល ចំណាយថវិកាទូទាត់សេវាមូលដ្ឋានសុខាភិបាល និងបើកផ្តល់តាវកាលិកសរុប ៦៥០ ២៣៥,៩៣លានរៀល សមាជិកទទួលតាវកាលិកសរុប ៨០ ៤០៣នាក់ (ស្រី ៧៤ ០៧៩នាក់) និងមានសមាជិកចូលប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាលសរុប ៧ ៧៧៣ ៧៩៩ដង (ស្រី ៥ ៧៣៦ ៣១៩ដង)។

❖ **ផ្នែកប្រាក់សោធន**

សហគ្រាស និងគ្រឹះស្ថានកំពុងដំណើរការក្នុងឆ្នាំ២០២៤ នេះ សរុប ២៤ ៨៩១សហគ្រាស មានសមាជិកចំនួន ១ ៥៧៤ ៤១៥នាក់ (ស្រី ៩៧០ ៧០០នាក់) និងទទួលបានចំណូលភាគទានសរុប ៧៩០ ១៦៤,០៥លានរៀល ចំណាយថវិកាបើកផ្តល់តាវកាលិកសរុប ១ ០២២,៦២លានរៀល សមាជិកទទួលតាវកាលិកសរុប ២ ៥៦៣នាក់ (ស្រី ៩៤៥នាក់)។

## ក. ការពង្រីក និងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម

### ក.១. ការចុះបញ្ជិកាក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថាន និងសមាជិក

**ប.ស.ស.** បានចុះបញ្ជិកាក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថានថ្មីសរុប ៦ ៧០៥សហគ្រាស មានសមាជិកចំនួន ៨៨០ ២៣៦នាក់ (ស្រី ៤៧០ ០២១នាក់) ក្នុងនោះតាមរបបភាគទានជាកាតព្វកិច្ចមានសហគ្រាសសរុប ៦ ៧០៥សហគ្រាស មានសមាជិកចំនួន ៣៤៧ ៧៦៧នាក់ (ស្រី ១៥០ ៩៧៩នាក់) និងតាមរបបភាគទានដោយស្ម័គ្រចិត្តមានសមាជិកចំនួន ៥៣២ ៤៦៩នាក់ (ស្រី ៣១៩ ០៤២នាក់)។

ក្រាហ្វិកទី១៖ ការចុះបញ្ជិកាក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថានថ្មីក្នុងឆ្នាំ២០២៤




ប្រភព៖ នាយកដ្ឋានបញ្ជិកា និងភាគទាន (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី១ តារាង១.១ ដល់តារាង១.៤.២)

ក្រាហ្វិកទី២៖ ការចុះបញ្ជិកាសមាជិកថ្មីក្នុងឆ្នាំ២០២៤




ប្រភព៖ នាយកដ្ឋានបញ្ជិកា និងភាគទាន (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី១ តារាង១.១ ដល់តារាង១.៤.២)

## ក.២. បច្ចុប្បន្នភាពក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថាន និងសមាជិក

បច្ចុប្បន្ន **ប.ស.ស.** មានក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថានសរុប ២៥ ១៦៤សហគ្រាស មានសមាជិកចំនួន ២ ៧១៥ ០៨៤នាក់ (ស្រី ១ ៥០៣ ៩០៧នាក់) ក្នុងនោះតាមរបបភាគទានជាកាតព្វកិច្ច មានសហគ្រាសចំនួន ២៥ ១៦៤សហគ្រាស មានសមាជិកចំនួន ២ ០៧៩ ២៨៥នាក់ (ស្រី ១ ១២១ ៤៤១នាក់) និងតាមរបបភាគទានដោយស្ម័គ្រចិត្តមានសមាជិកចំនួន ៦៣៥ ៧៩៩នាក់ (ស្រី ៣៨២ ៤៦៦នាក់)។

**តារាងទី១៖ បច្ចុប្បន្នភាពក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថាន និងសមាជិក**

| ល.រ | បរិយាយ | ឆ្នាំ2023 | | | ឆ្នាំ2024 | | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|---|---|
| | | សហ | សមាជិក | ស្រី | សហ | សមាជិក | ស្រី | |
| **សរុប (1+2)** | | **18,269** | **2,024,989** | **1,105,388** | **25,164** | **2,715,084** | **1,503,907** | **34.08%** |
| **1** | **តាមរបបភាគទានជាកាតព្វកិច្ច** | **18,269** | **1,956,955** | **1,062,703** | **25,164** | **2,079,285** | **1,121,441** | **6.25%** |
| 1.1 | បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ | 39 | 462,379 | 142,594 | 273 | 504,870 | 150,741 | 9.19% |
| 1.2 | បុគ្គលក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ | 18,230 | 1,494,576 | 920,109 | 24,891 | 1,574,415 | 970,700 | 5.34% |
| **2** | **តាមរបបភាគទានដោយស្ម័គ្រចិត្ត** | **ម.អ** | **68,034** | **42,685** | **ម.អ** | **635,799** | **382,466** | **834.53%** |
| 2.1 | សម្រាប់បុគ្គលស្វ័យនិយោជន៍ | ម.អ | 68,034 | 42,685 | ម.អ | 484,375 | 295,579 | 611.96% |
| 2.2 | សម្រាប់អ្នកក្នុងបន្ទុកសមាជិក ប.ស.ស. | ម.អ | 0 | 0 | ម.អ | 151,424 | 86,887 | 100.00% |

ប្រភព៖ នាយកដ្ឋានបញ្ជិកា និងភាគទាន (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី១ តារាង១.១ ដល់តារាង១.៤.២)

សម្គាល់៖ សហ មានន័យថា "សហគ្រាស" ម.អ មានន័យថា "មិនអនុវត្ត" បម្រែបម្រួល (%) គិតទៅលើសមាជិក

ក្រាហ្វិកទី៣៖ បច្ចុប្បន្នភាពក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថានសរុប គិតត្រឹមឆ្នាំ២០២៤




ប្រភព៖ នាយកដ្ឋានបញ្ជិកា និងភាគទាន (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី១ តារាង១.១ ដល់តារាង១.៤.២)

ក្រាហ្វិកទី៤៖ បច្ចុប្បន្នភាពសមាជិក ប.ស.ស. សរុប គិតត្រឹមឆ្នាំ២០២៤




ប្រភព៖ នាយកដ្ឋានបញ្ជិកា និងភាគទាន (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី១ តារាង១.១ ដល់តារាង១.៤.២)

តារាងទី២៖ បច្ចុប្បន្នភាពផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប

| បរិយាយ | ឆ្នាំ2023 | | | ឆ្នាំ2024 | | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|---|
| | សហ | សមាជិក | ស្រី | សហ | សមាជិក | ស្រី | |
| ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប | 1,233 | 779,972 | 610,008 | 1,321 | 898,343 | 678,333 | 15.18% |

ប្រភព៖ នាយកដ្ឋានបញ្ជិកា និងភាគទាន (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី១ តារាង១.៥)
សម្គាល់៖ សហ មានន័យថា "សហគ្រាស" បម្រែបម្រួល (%) គិតទៅលើសមាជិក

## ក.៣. ការចុះអធិការកិច្ចបញ្ជិកា

ការចុះអធិការកិច្ចបញ្ជិកា (ចុះស្រាវជ្រាវសហគ្រាសថ្មី ចែកលិខិតជូនដំណឹងអធិការកិច្ច អធិការកិច្ចចុះបញ្ជិកា និងសហគ្រាសគ្រឹះស្ថានដែលប្ដឹងទៅតុលាការ) មានចំនួន ៧ ៥៦៧លើក។

**តារាងទី៣៖ ការចុះអធិការកិច្ចបញ្ជិកា**

| ល.រ | បរិយាយ | ឆ្នាំ2023 | | ឆ្នាំ2024 | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| | | លើក | សហគ្រាស | លើក | សហគ្រាស | |
| **សរុប (1+2+3+4)** | | **3,013** | **8,545** | **7,567** | **19,291** | **125.75%** |
| 1 | ចុះស្រាវជ្រាវសហគ្រាសថ្មី | 485 | 2,502 | 92 | 355 | -85.81% |
| 2 | ចែកលិខិតជូនដំណឹងអធិការកិច្ច | 732 | 2,641 | 181 | 508 | -80.76% |
| 3 | អធិការកិច្ចចុះបញ្ជិកា | 1,796 | 3,394 | 7,286 | 18,420 | 442.72% |
| 4 | សហគ្រាសគ្រឹះស្ថានដែលប្ដឹងទៅតុលាការ | 0 | 8 | 8 | 8 | 0.00% |

ប្រភព៖ នាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី១ តារាង១.៦)
សម្គាល់៖ បម្រែបម្រួល (%) គិតទៅលើសហគ្រាស

## ក.៤. ការកសាងលិខិតបទដ្ឋាននៃការអនុវត្តរបបសន្តិសុខសង្គម

- ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** និងក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស.** ត្រូវបានបង្កើត៖
  - អនុក្រឹត្យលេខ ១០៥៦ អនក្រ.តត ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤ ស្ដីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម អាណត្តិទី២
  - អនុក្រឹត្យលេខ ៣០៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃបេឡាជាតិសន្តិសុខសង្គម។
- បានពង្រីកវិសាលភាពរបបសន្តិសុខសង្គមចំពោះក្រុមគោលដៅបន្ថែមរួមមាន៖
  - អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ ស្ដីពីការពង្រីកវិសាលភាពរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ
  - អនុក្រឹត្យលេខ ៣០៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការពង្រីកវិសាលភាពរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់និស្សិតនគរបាលនិងសិស្សនគរបាល។
- អនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីការបន្តសុពលភាពនៃអត្រាភាគទាននៅក្នុងអនុក្រឹត្យលេខ ២២១ អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា១៦ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

- ប្រកាសលេខ ២៣៥/២៤ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសេវាស្តារនីតិសម្បទាសេវា ឬការព្យាបាលនិងការថែទាំវេជ្ជសាស្ត្រដែលមិនរាប់បញ្ចូលនិងការផ្តល់សេវាបង្ការសុខភាព និងការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច
- របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ ដែលមានចែងនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវបានចាប់ផ្តើមធ្វើការសិក្សា និងស្រាវជ្រាវលើទិដ្ឋភាពគោលនយោបាយ ការគ្រប់គ្រងនិងប្រតិបត្តិការនៃការអនុវត្តរបស់ប្រទេសក្នុងតំបន់ ក៏ដូចជាអន្តរជាតិ លើសពីនេះ ថ្នាក់ដឹកនាំ **ប.ស.ស.** បានចូលរួមកិច្ចពិភាក្សាតុមូលរបស់ជំនាញការអាស៊ីស្តីពីកិច្ចគាំពារផ្នែកនិកម្មភាពការងារឆ្នាំ២០២៤ នៅថ្ងៃទី៩-១០ ខែតុលា ឆ្នាំ២០២៤ ដែលសហការរៀបចំឡើងដោយរាជរដ្ឋាភិបាលនៃប្រទេសជប៉ុន អង្គការអន្តរជាតិខាងការងារ និងអង្គភាពធានារ៉ាប់រងសំណងគ្រោះថ្នាក់ការងារអាស៊ីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី។

## ខ. ការពង្រឹង និងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម

### ខ.១. ការពង្រឹងសេវាទូទាត់ និងបើកផ្តល់តាវកាលិករបបសន្តិសុខសង្គម

សមាជិក **ប.ស.ស.** បានចូលប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាល (ដៃគូ និងក្រៅដៃគូ) សរុប ៧ ៧៩២ ៤៧៦ដង និងចំណាយមូលដ្ឋានសុខាភិបាលសរុប ៥១៣ ៥១៦,១៧លានរៀល ក្នុងនោះតាមរបបភាគទានជាកាតព្វកិច្ចមានចំនួន ៦ ៩៤០ ១៧៤ដង និងចំណាយមូលដ្ឋានសុខាភិបាល ៤៤៩ ៨៦០,២៤លានរៀល តាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួន ៨៥២ ៣០២ដង និងចំណាយមូលដ្ឋានសុខាភិបាល ៦៣ ៦៥៥,៩៣លានរៀល។

**តារាងទី៤៖ សមាជិកចូលប្រើប្រាស់សេវា និងការទូទាត់ជូនមូលដ្ឋានសុខាភិបាល**

| ល.រ | បរិយាយ | ឆ្នាំ2023 | | ឆ្នាំ2024 | | បម្រែបម្រួល (%) | |
|---|---|---|---|---|---|---|---|
| | | ដង | ចំណាយ (លានរៀល) | ដង | ចំណាយ (លានរៀល) | ដង | ចំណាយ (លានរៀល) |
| | **សរុប (1+2)** | **5,072,531** | **316,950.93** | **7,792,476** | **513,516.17** | **53.62%** | **62.02%** |
| **1** | **តាមរបបភាគទានជាកាតព្វកិច្ច** | **5,067,778** | **316,471.44** | **6,940,174** | **449,860.24** | **36.95%** | **42.15%** |
| 1.1 | បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ | 624,586 | 78,566.04 | 706,944 | 119,622.19 | 13.19% | 52.26% |
| 1.2 | បុគ្គលក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ | 4,443,192 | 237,905.40 | 6,233,230 | 330,238.05 | 40.29% | 38.81% |
| **2** | **តាមរបបភាគទានដោយស្ម័គ្រចិត្ត** | **4,753** | **479.50** | **852,302** | **63,655.93** | **17,831.87%** | **13,175.59%** |
| 2.1 | សម្រាប់បុគ្គលស្វ័យនិយោជន៍ | 4,753 | 479.50 | 724,953 | 58,746.39 | 15,152.54% | 12,151.70% |
| 2.2 | សម្រាប់អ្នកក្នុងបន្ទុកសមាជិក ប.ស.ស. | 0 | 0.00 | 127,349 | 4,909.54 | 100.00% | 100.00% |

ប្រភព៖ នាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាល (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី២ តារាង២.១ ដល់តារាង២.១.៦)

សមាជិក **ប.ស.ស.** ទទួលបានការទូទាត់តាវកាលិកសរុប ៩១ ១៧១នាក់ និងចំណាយអស់ទឹកប្រាក់ប្រមាណ ១៦៧ ២៨៥,១៨លានរៀល ក្នុងនោះតាមរបបភាគទានជាកាតព្វកិច្ចមានចំនួន ៨៩ ៧៩២នាក់ និងចំណាយអស់ទឹកប្រាក់ប្រមាណ ១៦៥ ៥៤១,៥២លានរៀល តាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួន ១ ៣៧៩នាក់ និងចំណាយអស់ទឹកប្រាក់ប្រមាណ ១ ៧៤៣,៦៥លានរៀល។ ជាមួយគ្នានេះ **ប.ស.ស.** បានផ្តល់តាវកាលិកផ្នែកប្រាក់សោធនដល់សមាជិកចំនួន ២ ៥៦៣នាក់ (ស្រី ៩៤៥នាក់) ដោយចំណាយអស់ទឹកប្រាក់

ប្រមាណ ១ ០២២,៦២លានរៀល និងបានផ្តល់សេវាស្តារនីតិសម្បទាដល់សមាជិកចំនួន ៤២៣ករណី (ស្រី ១៧៤ករណី) ដោយចំណាយអស់ទឹកប្រាក់ប្រមាណ ១៦៨,១៩លានរៀល។

**តារាងទី៥៖ ការផ្តល់ និងចំណាយតាវកាលិកដល់សមាជិក ប.ស.ស.**

| ល.រ | បរិយាយ | ឆ្នាំ2023 | | ឆ្នាំ2024 | | បម្រែបម្រួល (%) | |
|---|---|---|---|---|---|---|---|
| | | នាក់ | ចំណាយ (លានរៀល) | នាក់ | ចំណាយ (លានរៀល) | នាក់ | ចំណាយ (លានរៀល) |
| **សរុប (1+2)** | | **84,341** | **154,057.99** | **91,171** | **167,285.18** | **8.10%** | **8.59%** |
| **1** | **តាមរបបភាគទានជាកាតព្វកិច្ច** | **84,339** | **154,056.95** | **89,792** | **165,541.52** | **6.47%** | **7.45%** |
| 1.1 | បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ | 272 | 576.12 | 257 | 656.16 | -5.51% | 13.89% |
| 1.2 | បុគ្គលក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ | 84,067 | 153,480.82 | 89,535 | 164,885.37 | 6.50% | 7.43% |
| **2** | **តាមរបបភាគទានដោយស្ម័គ្រចិត្ត** | **2** | 1.04 | **1,379** | **1,743.65** | **68,850.00%** | **167,558.85%** |
| 2.1 | សម្រាប់បុគ្គលស្វ័យនិយោជន៍ | 2 | 1.04 | 1,264 | 1,578.52 | 63,100.00% | 151,680.77% |
| 2.2 | សម្រាប់អ្នកក្នុងបន្ទុកសមាជិក ប.ស.ស. | 0 | 0.00 | 115 | 165.13 | 100.00% | 100.00% |

ប្រភព៖ នាយកដ្ឋានតាវកាលិកសន្តិសុខសង្គម (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី២ តារាង២.៨ ដល់តារាង២.១៣)

## ខ.២. ការពង្រឹង និងបង្កើនគុណភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាល

➢ មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងថ្មី និងបច្ចុប្បន្នភាពមូលដ្ឋានសុខាភិបាល

**ប.ស.ស.** បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលដៃគូថ្មីចំនួន ៦៦មូលដ្ឋានសុខាភិបាល ដែលមានមូលដ្ឋានសុខាភិបាលសាធារណៈចំនួន ៣៦មូលដ្ឋានសុខាភិបាល និងមូលដ្ឋានសុខាភិបាលឯកជន ចំនួន ៣០មូលដ្ឋានសុខាភិបាល។

**តារាងទី៦៖ មូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងថ្មីជាមួយ ប.ស.ស.**

| ល.រ | បរិយាយ | ឯកតា | ឆ្នាំ2023 | ឆ្នាំ2024 | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| | **មូលដ្ឋានសុខាភិបាលចុះថ្មី (1+2)** | ចំនួនមូលដ្ឋានសុខាភិបាល | **31** | **66** | **112.90%** |
| **1** | **មូលដ្ឋានសុខាភិបាលសាធារណៈ** | | **18** | **36** | **100.00%** |
| 1.1 | មន្ទីរពេទ្យថ្នាក់ជាតិ | | 3 | 4 | 33.33% |
| 1.2 | មន្ទីរពេទ្យបង្អែក | | 1 | 2 | 100.00% |
| 1.3 | មណ្ឌលសុខភាព | | 14 | 30 | 114.29% |
| **2** | **មូលដ្ឋានសុខាភិបាលឯកជន** | | **13** | **30** | **130.77%** |

ប្រភព៖ នាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាល (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី២ តារាង២.៣.១ ដល់តារាង២.៣.២)

បច្ចុប្បន្នភាពមូលដ្ឋានសុខាភិបាលសរុបមានចំនួន ១ ៥៩៥មូលដ្ឋានសុខាភិបាល ក្នុងនោះ មូលដ្ឋានសុខាភិបាលសាធារណៈចំនួន ១ ៤៣១មូលដ្ឋានសុខាភិបាល និងមូលដ្ឋានសុខាភិបាលឯកជនចំនួន ១៦៤មូលដ្ឋានសុខាភិបាល។

ក្រាហ្វិកទី៥៖ បច្ចុប្បន្នភាពមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.




ប្រភព៖ នាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាល (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី២ តារាង២.៣)

## គ. ការលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម

### គ.១. ការពង្រឹងសេវាផ្តល់ព័ត៌មានអតិថិជន និងដោះស្រាយបណ្តឹង

នៅក្នុងឆ្នាំ២០២៤ **ប.ស.ស.** បានទទួលបណ្តឹងសរុប ៨៣០ករណី បានដោះស្រាយបណ្តឹងមានចំនួន ៩៦២ករណី បណ្តឹងដោះស្រាយមិនទាន់រួចរាល់មានចំនួន ១៣០ករណី និងទទួលបានសំណូមពរពីសមាជិកសរុប ៥៨៧ករណី។

**តារាងទី៧៖ ការដោះស្រាយបណ្តឹង និងសំណូមពរទទួលបានពីសមាជិក**

| ល.រ | បរិយាយ | ឆ្នាំ2023 | ឆ្នាំ2024 | បម្រែបម្រួល (%) |
|---|---|---|---|---|
| **ក. បណ្តឹង និងសំណូមពរទទួលបានពីមជ្ឈមណ្ឌលព័ត៌មាន** | | | | |
| 1 | ចំនួនបណ្តឹង | 730 | 814 | 11.51% |
| 2 | ចំនួនដោះស្រាយ | 715 | 954 | 33.43% |
| 3 | បណ្តឹងនៅសល់ | 0 | 122 | 100.00% |
| 4 | ចំនួនសំណូមពរ | 260 | 584 | 124.62% |
| **ខ. បណ្តឹង និងសំណូមពរទទួលបានពីប្រព័ន្ធបណ្តឹងអនាមិក** | | | | |
| 1 | ចំនួនបណ្តឹង | មិនទាន់អនុវត្ត | 16 | 100.00% |
| 2 | ចំនួនដោះស្រាយ | មិនទាន់អនុវត្ត | 8 | 100.00% |
| 3 | បណ្តឹងនៅសល់ | មិនទាន់អនុវត្ត | 8 | 100.00% |
| 4 | ចំនួនសំណូមពរ | មិនទាន់អនុវត្ត | 3 | 100.00% |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.១)

តារាងទី៨៖ ការឆ្លើយតបសំណួរទៅសមាជិក ប.ស.ស. តាមបណ្តាញសង្គម និង Call-Center 1286 និង 1297

| ល.រ | បរិយាយ | ឆ្នាំ2023 | ឆ្នាំ2024 | បម្រែបម្រួល (%) |
|---|---|---|---|---|
| **សរុប (1+2+3)** | | **176,149** | **391,622** | **122.32%** |
| 1 | 1286 | 118,132 | 291,129 | 146.44% |
| 2 | 1297 | 0 | 43,843 | 100.00% |
| 3 | បណ្តាញសង្គម | 58,017 | 56,650 | -2.36% |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.២)

## គ.២. ការសហការបង្កើនការផ្សព្វផ្សាយ អប់រំ និងបង្ការ

➢ ការផ្សព្វផ្សាយ និងអប់រំ

ដើម្បីលើកកម្ពស់ការយល់ដឹងដល់សមាជិក **ប.ស.ស.** ក៏ដូចជាសាធារណជនអំពីអត្ថប្រយោជន៍នៃការអនុវត្តរបបសន្តិសុខសង្គម និងការបង្ការគ្រោះថ្នាក់ការងារ **ប.ស.ស.** បានធ្វើការផ្សព្វផ្សាយតាមគ្រប់រូបភាព និងគ្រប់ទម្រង់។

ក្រាហ្វិកទី៦៖ ការផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គម (គិតជាលើក)




ប្រភព៖ នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.៣ ដល់តារាង៣.៤)

ក្រាហ្វិកទី៧៖ ការផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គម (អ្នកចូលរួមគិតជានាក់)




ប្រភព៖ នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.៣ ដល់តារាង៣.៤)

តារាងទី៩៖ ការងារអប់រំ និងផ្សព្វផ្សាយ

| បរិយាយ | ឆ្នាំ2023 | | | ឆ្នាំ2024 | | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|---|
| | លើក | អ្នកចូលរួម | ស្រី | លើក | អ្នកចូលរួម | ស្រី | |
| ការផ្សព្វផ្សាយអំពីគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ | 35 | 6,860 | 6,153 | 43 | 3,176 | 2,105 | -53.70% |
| ការផ្សព្វផ្សាយអំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ដល់កម្មករនិយោជិត | 33 | 2,237 | 1,648 | 65 | 6,539 | 5,062 | 192.31% |
| ការផ្សព្វផ្សាយអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដល់កម្មករនិយោជិត និងអ្នកបើកបរ | 162 | 26,519 | 20,366 | 259 | 40,981 | 25,473 | 54.53% |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.៥ ដល់តារាង៣.៧)
សម្គាល់៖ បម្រែបម្រួល (%) គិតទៅលើអ្នកចូលរួម

ក្រាហ្វិកទី៨៖ ការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គម និងសារព័ត៌មានឆ្នាំ២០២៤




ប្រភព៖ នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.៨)

ក្រាហ្វិកទី៩៖ ការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គម និងសារព័ត៌មានរវាងឆ្នាំ២០២៣ និងឆ្នាំ២០២៤




ប្រភព៖ នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.៨)

តារាងទី១០៖ ការផលិតខិត្តប័ណ្ណ Poster បទយកការណ៍ និងស្ពតផ្សព្វផ្សាយរបស់ ប.ស.ស.

| ល.រ | បរិយាយ | ឯកតា | ឆ្នាំ2023 | ឆ្នាំ2024 | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| 1 | ការផលិតខិត្តប័ណ្ណ និងផ្ទាំងរូបភាព | ខិត្តប័ណ្ណ | 172 | 483 | 180.81% |
| 2 | បទយកការណ៍ | វីដេអូ | 3 | 6 | 100.00% |
| 3 | ការផលិតវីដេអូផ្សព្វផ្សាយ | វីដេអូ | 18 | 29 | 61.11% |
| **សរុប (1+2+3)** | | **ខិត្តប័ណ្ណ/វីដេអូ** | **193** | **518** | **168.39%** |

ប្រភព៖ នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.៩)

➢ ការរៀបចំកម្រងឯកសារជំនួយស្មារតីវិស័យសន្តិសុខសង្គម




**ប.ស.ស.** បានរៀបចំកម្រងឯកសារជំនួយស្មារតីវិស័យសន្តិសុខសង្គម ក្នុងគោលបំណងសម្រាប់សាធារណជនប្រើប្រាស់ និងសិក្សាពីការវិវត្ត វិធានលក្ខខណ្ឌ តាវកាលិក ក្រសួង អង្គភាព ស្ថាប័នពាក់ព័ន្ធនានា ដោយក្នុងនោះបានរៀបចំរួចរាល់ក្នុងខែកញ្ញា ឆ្នាំ២០២៤ និងបានធ្វើបច្ចុប្បន្នភាពឡើងវិញនៅអំឡុងខែធ្នូ ឆ្នាំ២០២៤។ កម្រងឯកសារជំនួយស្មារតីនេះ មានបែងចែកជា ៤ជំពូករួមមាន៖

- ជំពូកទី១ សញ្ញាណប្រព័ន្ធសន្តិសុខសង្គមនៅលើសកលលោក
- ជំពូកទី២ ប្រព័ន្ធសន្តិសុខសង្គមនៅប្រទេសកម្ពុជា
- ជំពូកទី៣ ការអនុវត្តរបបសន្តិសុខសង្គមនៅប្រទេសកម្ពុជា
- ជំពូកទី៤ ការចូលរួមអនុវត្តកម្មវិធីជំនួយសង្គមដោយ **ប.ស.ស.**។

### គ.៣. ការវាយតម្លៃការយល់ដឹង និងភាពពេញចិត្ត

**ប.ស.ស.** ចាប់ផ្តើមធ្វើការសិក្សាវាយតម្លៃការយល់ដឹង និងភាពពេញចិត្តរបស់សមាជិក **ប.ស.ស.** នៅដំណាច់ឆ្នាំ២០២៣ និងបានចេញជារបាយការណ៍លទ្ធផលនៃការអង្កេតនៅឆ្នាំ២០២៤ ដោយក្នុងនោះសមាជិក **ប.ស.ស.** ៩៧% ពេញចិត្តលើការទទួលបានអត្ថប្រយោជន៍ពី **ប.ស.ស.** និង ៩៣% មានការពេញចិត្តលើការផ្តល់សេវា (**ប.ស.ស.** និងមូលដ្ឋានសុខាភិបាល) និង ៨៧% មានការយល់ដឹងពីការអនុវត្តរបបសន្តិសុខសង្គម ដែលការរៀបចំនេះមានការចូលរួមនិងឧបត្ថម្ភគាំទ្រពីអង្គការ GIZ ។

## ឃ. ការពង្រឹងការគ្រប់គ្រង និងចាត់ចែងមូលនិធិសន្តិសុខសង្គម

### ឃ.១. ពង្រឹងការបង់ភាគទានតាមរយៈការត្រួតពិនិត្យតាមដាន និងចាត់វិធានការ

➢ ការងារប្រមូលភាគទាន

នៅក្នុងឆ្នាំ២០២៤ នេះ **ប.ស.ស.** មានសមាជិកជាប់ភាគទានសរុបចំនួន ២ ៤៣៩ ៣០១នាក់ (ស្រី ១ ៣៣៧ ០២៣នាក់) ក្នុងនោះសមាជិកបានបង់ភាគទានមក **ប.ស.ស.** ចំនួន ២ ១១៨ ១៥៤នាក់ (ស្រី ១ ២១០ ២១២នាក់) និងទទួលបានភាគទានចំនួន ១ ៥៨៣ ៦៣១,៧៨លានរៀល។

ក្រាហ្វិកទី១០៖ ចំនួនសមាជិកជាប់ភាគទានតាមរបបភាគទានជាកាតព្វកិច្ច និងដោយស្ម័គ្រចិត្ត




ប្រភព៖ នាយកដ្ឋានបញ្ជិកា និងភាគទាន (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៤ តារាង៤.១. ដល់តារាង៤.១.៣)

ក្រាហ្វិកទី១១៖ ចំនួនសមាជិកបានបង់ភាគទានតាមរបបភាគទានជាកាតព្វកិច្ច និងដោយស្ម័គ្រចិត្ត




ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន និងនាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៤ តារាង៤.១ ដល់តារាង៤.១.៣)

សម្គាល់៖ សមាជិក គិតជានាក់ ភាគទាន គិតជាលានរៀល

**ក្រាហ្វិកទី១២៖ ចំនួនសមាជិកបានបង់ភាគទានតាមក្រុមគោលដៅនីមួយៗ**




ប្រភព៖ នាយកដ្ឋានបញ្ជិកានិងភាគទាន និងនាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៤ តារាង៤.១ ដល់តារាង៤.១.៣)

សម្គាល់៖ សមាជិក គិតជានាក់ ភាគទាន គិតជាលានរៀល

- ការងារត្រួតពិនិត្យតាមដាន និងចាត់វិធានការ

បានធ្វើការតាមដាន ត្រួតពិនិត្យការអនុវត្តការបង់ភាគទាន ការប្រកាសភាគទានរបស់សហគ្រាស គ្រឹះស្ថាន ជាប់ជាប្រចាំខែ ដោយក្នុងនោះបានកំណត់គោលដៅនៃសហគ្រាស គ្រឹះស្ថាន ដែលអនុវត្តមិនត្រឹមត្រូវសរុបជាមធ្យមចំនួន ១ ០០០សហគ្រាស គ្រឹះស្ថាន ក្នុង ១ខែ និងបានចាត់វិធានការតាមនីតិវិធី ដោយពិន័យអន្តរការណ៍ចំពោះសហគ្រាស គ្រឹះស្ថានសរុបចំនួន ១៨៤សហគ្រាស។

**តារាងទី១១៖ ការចុះអធិការកិច្ចបង់ភាគទាន**

| ល.រ | បរិយាយ | ឆ្នាំ2023 | | ឆ្នាំ2024 | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| | | លើក | សហគ្រាស | លើក | សហគ្រាស | |
| សរុប (1+2+3+4) | | 3,325 | 14,275 | 3,700 | 17,359 | 21.60% |
| 1 | ចែកលិខិតជូនដំណឹងជាប់ភាគទាន | 0 | 0 | 0 | 0 | 0.00% |
| 2 | ចែកលិខិតបង់ភាគទាន | 1,618 | 10,869 | 1,815 | 13,484 | 24.06% |
| 3 | ចុះអធិការកិច្ចបង់ភាគទាន | 1,707 | 3,406 | 1,885 | 3,875 | 13.76% |
| 4 | សហគ្រាសគ្រឹះស្ថានដែលប្ដឹងទៅតុលាការ | 0 | 0 | 0 | 0 | 0.00% |

ប្រភព៖ នាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.១០)

សម្គាល់៖ បម្រែបម្រួល (%) គិតទៅលើសហគ្រាស

តារាងទី១២៖ ការចុះអធិការកិច្ចពិន័យអន្តរការណ៍

| ល.រ | បរិយាយ | ឆ្នាំ2023 | | ឆ្នាំ2024 | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| | | សហគ្រាស | កម្មករនិយោជិត | សហគ្រាស | កម្មករនិយោជិត | |
| **សរុប (1+2+3+4)** | | **72** | **5,299** | **144** | **35,354** | **567.18%** |
| 1 | មិនអនុវត្តកាតព្វកិច្ចរាយការណ៍អំពីចំនួនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ | 39 | 1,227 | 74 | 4,985 | 306.28% |
| 2 | មិនអនុវត្តកាតព្វកិច្ចនៃការបង់ភាគទានតាមកាលកំណត់ | 27 | 3,839 | 21 | 3,142 | -18.16% |
| 3 | ប្រកាសប្រាក់ឈ្នួលជាប់ភាគទានមិនត្រឹមត្រូវ | 0 | 0 | 63 | 27,029 | 100.00% |
| 4 | មិនអនុវត្តកាតព្វកិច្ចចុះបញ្ជីសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | 6 | 233 | 3 | 198 | -15.02% |

ប្រភព៖ នាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៣ តារាង៣.១៣)

សម្គាល់៖ សហគ្រាស (មិនអាចបូកបញ្ចូលគ្នាបានទេ ដោយសារសហគ្រាស១ អាចមានជាប់ពិន័យលើសពី១ ក្នុងចំណោមពិន័យទាំង ៤ខាងលើ ដោយឡែកកម្មករនិយោជិតអាចបូកបញ្ចូលគ្នាបាន) បម្រែបម្រួល (%) គិតទៅលើកម្មករនិយោជិត

### ឃ.២. ការវាយតម្លៃស្ថានភាពហានិភ័យហិរញ្ញវត្ថុសន្តិសុខសង្គម

និរន្តរភាពមូលនិធិសន្តិសុខសង្គម និងការពង្រីកវិសាលភាពរបបសន្តិសុខសង្គម ចាំបាច់ត្រូវបានធានាឱ្យស្របទៅតាមក្របខណ្ឌពេលវេលា ស្ថានភាពសង្គម-សេដ្ឋកិច្ច ប្រជាសាស្ត្រ គោលនយោបាយ និងការគ្រប់គ្រងតាមការសិក្សាតាមដាននិងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុក្នុងរបបសន្តិសុខសង្គមទៅតាមផ្នែក និងក្រុមគោលដៅនីមួយៗជាប់ជាប្រចាំ។ ស្របគ្នានេះដែរ ការសិក្សាតាមដាននិងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបបសន្តិសុខសង្គម ក៏មានចែងក្នុងគោលការណ៍សន្តិសុខសង្គមអន្តរជាតិ និងក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម ដោយបានកំណត់ក្របខណ្ឌពេលវេលាក្នុងការសិក្សាតាមផ្នែកនីមួយៗបានយ៉ាងច្បាស់។ ដើម្បីអនុវត្តការងារខាងលើឱ្យមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងទាន់ពេលវេលា ក្នុងនោះ **ប.ស.ស.** ៖

- បានបង្កើតគណៈកម្មការដឹកនាំក្រុមការងារបច្ចេកទេសសម្រាប់ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុរបបសន្តិសុខសង្គម (គ.វ.ហ) របស់បេឡាជាតិសន្តិសុខសង្គម
- បានបង្កើតក្រុមការងារតាមដាន និងវាយតម្លៃនិរន្តរភាពមូលនិធិសន្តិសុខសង្គម
- បានរៀបចំផលិតរបាយការណ៍វិភាគ និងតាមដានស្ថានភាពប្រតិបត្តិការនិងហិរញ្ញវត្ថុជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ គោរពជូន **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស.** និង **សម្តេចធិបតី**។

## ង. ការអភិវឌ្ឍសមត្ថភាពបេឡាជាតិសន្តិសុខសង្គម

### ង.១. ការអភិវឌ្ឍធនធានមនុស្ស

- បច្ចុប្បន្នភាពមន្ត្រី និងបុគ្គលិក **ប.ស.ស.**

បច្ចុប្បន្ន **ប.ស.ស.** មានស្នាក់ការកណ្តាល និងសាខាតាមបណ្តាខេត្ត ក្រុង ស្រុក ខណ្ឌ សរុប ៣៨ទីតាំង ដែលមានថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកបម្រើការងារសរុបចំនួន ២ ២៨៥នាក់ (ស្រី ១ ០៩០នាក់) ក្នុងនោះមានមន្ត្រីចំនួន ៣១៨នាក់ (ស្រី ៩៨នាក់) និងបុគ្គលិកជាប់កិច្ចសន្យាមានចំនួន ១ ៩៦៧នាក់ (ស្រី ៩៩២នាក់)។

តារាងទី១៣៖ បច្ចុប្បន្នភាពមន្ត្រី និងបុគ្គលិក ប.ស.ស.

| ល.រ | បរិយាយ | ឆ្នាំ2023 | | ឆ្នាំ2024 | | បម្រែបម្រួល (%) | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| **សរុប (1+2)** | | **1,926** | **928** | **2,285** | **1,090** | **18.64%** | **17.46%** |
| 1 | ស្នាក់ការកណ្ដាល | 1,307 | 618 | 1,494 | 734 | 14.31% | 18.77% |
| 2 | សាខា | 619 | 310 | 791 | 356 | 27.79% | 14.84% |

ប្រភព៖ នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៥ តារាង៥.១ ដល់តារាង៥.១ ដល់តារាង៥.១.១)

➢ ការបណ្ដុះបណ្ដាល និងសិក្ខាសាលា

ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក **ប.ស.ស.** បានចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាសរុបចំនួន ១៤៤វគ្គ/លើក ដែលមានអ្នកចូលរួមចំនួន ១ ៧៥៧នាក់ (ស្រី ៦៨១នាក់) ក្នុងនោះបានចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាក្នុងប្រទេសចំនួន ១២៨វគ្គ/លើក ដែលមានអ្នកចូលរួមចំនួន ១ ៧១៤នាក់ (ស្រី ៦៦៥នាក់) និងបានចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាក្រៅប្រទេសចំនួន ១៦វគ្គ/លើក ដែលមានអ្នកចូលរួមចំនួន ៤៣នាក់ (ស្រី ១៦នាក់)។

តារាងទី១៤៖ ការងារបណ្ដុះបណ្ដាលធនធានមនុស្ស

| ល.រ | បរិយាយ | ឆ្នាំ2023 | | | ឆ្នាំ2024 | | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|---|---|
| | | វគ្គ/លើក | សរុប | ស្រី | វគ្គ/លើក | សរុប | ស្រី | |
| **សរុប (1+2)** | | **80** | **1,857** | **768** | **144** | **1,757** | **681** | **-5.39%** |
| **1** | **ការចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា** | **76** | **1,836** | **764** | **138** | **1,740** | **678** | **-5.23%** |
| 1.1 | ក្នុងប្រទេស | 62 | 1,794 | 748 | 126 | 1,706 | 664 | -4.91% |
| 1.2 | ក្រៅប្រទេស | 14 | 42 | 16 | 12 | 34 | 14 | -19.05% |
| **2** | **ការចូលរួមទស្សនកិច្ចសិក្សា** | **4** | **21** | **4** | **6** | **17** | **3** | **-19.05%** |
| 2.1 | ក្នុងប្រទេស | 0 | 0 | 0 | 2 | 8 | 1 | 100.00% |
| 2.2 | ក្រៅប្រទេស | 4 | 21 | 4 | 4 | 9 | 2 | -57.14% |

ប្រភព៖ នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី៥ តារាង៥.២ ដល់តារាង៥.២.១)
សម្គាល់៖ បម្រែបម្រួល (%) គិតទៅលើសរុប

### ង.២. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន គឺជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍ និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមបន្ថែម តាមរយៈការផ្ដល់សេវាបានទាន់ពេលវេលា។ ជាមួយគ្នានេះដែរ ក្នុងឆ្នាំ២០២៤នេះ **ប.ស.ស.** បានសាងសង់រួចរាល់នៅអគារសាខា **ប.ស.ស.** ថ្មី តាមរាជធានី ខេត្តបានចំនួន ១០អគារ និងកំពុងសាងសង់ចំនួន ៧អគារ ដែលនឹងត្រូវដាក់ឱ្យដំណើរការក្នុងឆ្នាំ២០២៥។

### ង.៣. ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ

**ប.ស.ស.** បានបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិលើគម្រោងអភិវឌ្ឍន៍របបសន្តិសុខសង្គមដូចខាងក្រោម៖

**១. កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិខាងការងារ (ILO)**

- ➢ គម្រោងស្តីពី ការវាយតម្លៃទំនើបភាវូបនីយកម្ម **ប.ស.ស.** ដំណាក់កាលទី២ (Project on NSSF Modernization Readiness Assessment Phase II)
- ➢ គម្រោងស្តីពី ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុរបស់ **ប.ស.ស.** (Project on Actuarial Valuation of NSSF)

- គម្រោងស្តីពី ការវាយតម្លៃផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ សម្រាប់អភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន **ប.ស.ស.** (Project on Assessment of the 5-Year ICT Strategic Plan of NSSF)
- គម្រោងស្តីពី ការពង្រឹងការចុះបញ្ជីសមាជិក **ប.ស.ស.** (Extension of NSSF Membership through Registration Campaign)
- គម្រោងស្តីពី ផែនការសម្រាប់ការកសាងសមត្ថភាពផ្នែកវិនិយោគ អភិបាលកិច្ច និងគ្រប់គ្រងហានិភ័យ (Work Plan for Investment, Governance, and Risk Management Capacity Building)
- គម្រោងស្តីពី ការអភិវឌ្ឍរបាយការណ៍ប្រចាំឆ្នាំ២០២៣ និងសៀវភៅស្ថិតិស្តីពីរបបសន្តិសុខសង្គមរបស់ **ប.ស.ស.** (Project on Development the 2023 Annual Report and Statistical Book)។

**២. កិច្ចសហប្រតិបត្តិការជាមួយអង្គការហ្គ្រេត (GRET)**

- អនុស្សរណៈនៃការយោគយល់គ្នាសម្រាប់អនុវត្តគម្រោងស្តីពី ការពង្រីករបបសន្តិសុខសង្គមសម្រាប់បុគ្គលស្វ័យនិយោជន៍ (គម្រោង A4S)
- អនុស្សរណៈនៃការយោគយល់គ្នាសម្រាប់អនុវត្តគម្រោងស្តីពី ការពង្រឹងការបន្សាំរបបធានារ៉ាប់រងសង្គម (គម្រោង SASI)។

**៣. កិច្ចសហការជាមួយកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ)** តាមរយៈអនុស្សរណៈនៃការយោគយល់គ្នារវាងបេឡាជាតិសន្តិសុខសង្គម និងកម្មវិធីកិច្ចគាំពារសង្គមនៃកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់

- គម្រោងអភិវឌ្ឍន៍ប្រព័ន្ធចុះបញ្ជិកា និងការបង់ភាគទានលើគេហទំព័រ (Web Based Registration and Contribution Application) ជាមួយក្រុមហ៊ុន OPTISTECH
- គម្រោងស្តីពី ការស្ទង់មតិពីភាពពេញចិត្តរបស់សមាជិក **ប.ស.ស.** ក្នុងការផ្តល់សេវារបស់ **ប.ស.ស.** ជូនសមាជិករបស់ខ្លួន ជាមួយក្រុមហ៊ុន Indochina Research (Cambodia)
- គម្រោងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងតាវកាលិកលើគេហទំព័រ (Web Based Application for Benefit Management System) ជាមួយក្រុមហ៊ុន Polygram។

**៤. កិច្ចសហប្រតិបត្តិការជាមួយអង្គភាពសុខុមាលភាព និងសំណងគ្រោះថ្នាក់ការងារ (COMWEL)** តាមរយៈអនុស្សរណៈនៃការយោគយល់គ្នាស្តីពី ការធានារ៉ាប់រងហានិភ័យការងាររវាងអង្គភាពសុខុមាលភាព និងសំណងគ្រោះថ្នាក់ការងារនៃសាធារណរដ្ឋកូរ៉េ និងបេឡាជាតិសន្តិសុខសង្គម និងកិច្ចព្រមព្រៀងអនុវត្ត (Implementation Agreement) លើគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការស្តីពី កម្មវិធីពិគ្រោះយោបល់គោលនយោបាយសម្រាប់ការបង្កើតប្រព័ន្ធស្តារនីតិសម្បទា និងប្រព័ន្ធវេជ្ជសាស្ត្រកម្ពុជា រវាងអង្គភាពសុខុមាលភាព និងសំណងគ្រោះថ្នាក់ការងារ (COMWEL) នៃសាធារណរដ្ឋកូរ៉េ និង **ប.ស.ស.** រយៈពេលអនុវត្តគ្រោងចំនួន ៣ឆ្នាំ (២០២២-២០២៤)។

## ង.៤. ប្រព័ន្ធប្រតិបត្តិការ និងសន្តិសុខបច្ចេកវិទ្យា

➢ បរិវត្តកម្មបច្ចេកវិទ្យាក្នុងបេឡាជាតិសន្តិសុខសង្គម

**ប.ស.ស.** កំពុងបង្កើនការប្រើប្រាស់បច្ចេកវិទ្យាដើម្បីធ្វើឱ្យការប្រតិបត្តិការប្រចាំថ្ងៃកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាព។ ការផ្លាស់ប្តូរការចុះបញ្ជិកានិងបង់ភាគទាន និងប្រព័ន្ធផ្សេងៗទៀតពីទម្រង់ Desktop Application ទៅជា Web Application វិញ។

| | | | |
|---|---|---|---|
| ១ | **ប្រព័ន្ធចុះបញ្ជី និងបង់ភាគទាន តាមកម្មវិធី គេហទំព័រ NSSF Enterprise User** | - ចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន<br>- ត្រួតពិនិត្យព័ត៌មានសហគ្រាស ផ្ទាល់ខ្លួន<br>- ចុះបញ្ជីសមាជិក<br>- ត្រួតពិនិត្យព័ត៌មានសមាជិក<br>- ប្រកាសសមាជិក<br>- គណនាភាគទានដែលត្រូវបង់<br>- បង់ភាគទានតាមរយៈទូរសព្ទ ជាមួយធនាគារដៃគូ |  |
| ២ | **ប្រព័ន្ធ HSPIS តាមកម្មវិធី គេហទំព័រ** | - ឆែកសុពលភាពសមាជិក និង ស្កែនម្រាមដៃ<br>- ព្រីនទម្រង់ចូលប្រើប្រាស់សេវា<br>- បញ្ចូលការប្រើប្រាស់សេវា<br>- គណនាប្រាក់បំណាច់ប្រចាំថ្ងៃ ផ្នែកថែទាំសុខភាព<br>- ទូទាត់សំណងវេជ្ជសាស្ត្រផ្នែក ថែទាំសុខភាពទៅមូលដ្ឋាន សុខាភិបាល<br>- ទាញរបាយការណ៍ |  |
| ៣ | **កម្មវិធីគេហទំព័រ ការស្នើចុះកិច្ច ព្រមព្រៀងរបស់ មូលដ្ឋានសុខាភិ- បាល** | - ស្នើសុំចុះកិច្ចព្រមព្រៀងរបស់ មូលដ្ឋានសុខាភិបាល<br>- ទូទាត់ចំណាយរបស់មូលដ្ឋាន សុខាភិបាល<br>- តាមដានឯកសារ |  |

| | | | |
|---|---|---|---|
| ៤ | **កម្មវិធីទូរសព្ទដៃសម្រាប់សមាជិក**<br>**NSSF Member App** | - ត្រួតពិនិត្យសុពលភាព<br>- ត្រួតពិនិត្យព័ត៌មានផ្ទាល់ខ្លួន<br>- ត្រួតពិនិត្យរបាយការណ៍បង់ភាគទាន<br>- ស្វែងរកសាខា ប.ស.ស.<br>- ស្វែងរកមូលដ្ឋានសុខាភិបាលដៃគូ<br>- ចុះបញ្ជីបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុក<br>- ត្រួតពិនិត្យរបាយការណ៍ចូលប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាល<br>- បញ្ចូលការទាមទារតេរកាលិក | <br> |
| ៥ | **កម្មវិធីទូរសព្ទសម្រាប់មូលដ្ឋានសុខាភិបាល**<br>**Agent Mobile App** | - ឆែកសុពលភាព និងព័ត៌មានរបស់សមាជិក<br>- បញ្ចូលការប្រើប្រាស់សេវា<br>- បញ្ចូលការទាមទារប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល<br>- បញ្ចូលការទាមទារសំណងវេជ្ជសាស្ត្រ និងតាមដាន<br>- ស្វែងរកសាខា ប.ស.ស. | <br> |

## ង.៥. ការងារគាំទ្រទូទៅ

- ការងាររបាយការណ៍ និងស្ថិតិ
  - បានរៀបចំរបាយការណ៍លទ្ធផលការងារសម្រេចបានរបស់ **ប.ស.ស.** ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
  - បានរៀបចំរបាយការណ៍សង្ខេបអំពីវិស័យសន្តិសុខសង្គមជាប់ជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ
  - បានចងក្រង និងបញ្ចូលទិន្នន័យស្ថិតិនៃការអនុវត្តរបបសន្តិសុខសង្គមជាប់ជាប្រចាំ
  - បានផ្តល់ជូនទិន្នន័យស្ថិតិតាមការស្នើសុំរបស់ក្រសួង ស្ថាប័ន អង្គភាព និងភាគីពាក់ព័ន្ធផ្សេងៗ ស្តីពីការអនុវត្តរបបសន្តិសុខសង្គមសរុបប្រមាណចំនួន ២០ក្រសួង ស្ថាប័ន អង្គភាព។

- ការងារចូលរួមកសាង និងផ្តល់ធាតុចូលលើលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធជាមួយ **ប.ស.ស.**

**ប.ស.ស.** បានចូលរួមប្រជុំ និងសិក្ខាសាលាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមផ្តល់ធាតុចូល និងពិនិត្យកែសម្រួលផ្តល់យោបល់លើការរៀបចំ និងកសាងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធប្រព័ន្ធគាំពារសង្គម ប្រព័ន្ធជំនួយសង្គម វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបចំនួន ៨៧លើក។

- ការងារអនុវត្តកម្មវិធីនយោបាយ គោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធ
  - បានចូលរួមផ្តល់ធាតុចូលលើសេចក្តីព្រាងកម្មវិធីនយោបាយ គោលនយោបាយ និងយុទ្ធសាស្ត្រ សរុបចំនួន ១២លើក
  - បានរៀបចំឆ្លើយតបវឌ្ឍនភាពនៃការអនុវត្តកម្មវិធីនយោបាយ គោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធស្របទៅតាមវដ្ត និងតាមតម្រូវការជាក់ស្តែងចំនួន ១១លើក
  - បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត និងអ្នកក្នុងបន្ទុកសមាជិក **ប.ស.ស.** ជាប្រចាំថ្ងៃ អនុវត្តចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ និងប្រចាំខែ អនុវត្តចាប់ពីខែមីនា ឆ្នាំ២០២៤
  - បានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំសប្តាហ៍នៃការអនុវត្តអនុសាសន៍ទាំង១០ចំណុចរបស់ **សម្តេចធិបតី** អនុវត្តចាប់ពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤
  - បានរៀបចំផែនការសកម្មភាពឆ្នាំ២០២៤ របស់ **ប.ស.ស.** និងកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៥ របស់ **ប.ស.ស.**
  - បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០២៣ របស់ **ប.ស.ស.** និងកំពុងរៀបចំសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០២៤ របស់ **ប.ស.ស.**
  - បានប្រមូល និងចងក្រងផែនការសកម្មភាពឆ្នាំ២០២៤ និងឆ្នាំ២០២៥ របស់អង្គភាពក្រោមឱវាទ **ប.ស.ស.**
  - បានរៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាប្រចាំខែ របស់នាយកដ្ឋាន និងអង្គភាព
  - បានរៀបចំ និងប្រមូលចងក្រងផែនការសកម្មភាពប្រចាំត្រីមាស របស់សាខា **ប.ស.ស.** ខេត្ត ខណ្ឌ
  - បានរៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាប្រចាំខែ របស់សាខា **ប.ស.ស.** ខេត្ត ខណ្ឌ។
- រៀបចំឯកសារជំនួយស្មារតី និងបទបង្ហាញស្តីពីវឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គម
  - បានរៀបចំឯកសារជំនួយស្មារតីជូនថ្នាក់ដឹកនាំសម្រាប់ចូលរួមកិច្ចប្រជុំនានាសរុបចំនួន ៥៣លើក
  - បានរៀបចំស្លាយបទបង្ហាញស្តីពីវឌ្ឍនភាពនៃការអនុវត្តរបបសន្តិសុខសង្គមចំនួន ៤១លើក។
- ឆ្លើយតបវឌ្ឍនភាពជាមួយអង្គការ ឬស្ថាប័នអន្តរជាតិផ្សេងៗ
  - បានរៀបចំឆ្លើយតបវឌ្ឍនភាពជាមួយអង្គការដៃគូ និងស្ថាប័នអន្តរជាតិនានាសរុបចំនួន ២២លើក
  - បានរៀបចំឆ្លើយតបលើករណីសំណើសុំរៀបចំចំណុចពិភាក្សា បញ្ហាប្រឈម សំណូមពរ ទិសដៅអនុវត្តបន្ត និងឯកសារពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់ធាតុចូលសម្រាប់សេចក្តីព្រាងសុន្ទរកថាជូន **សម្តេចធិបតី** នាយករដ្ឋមន្ត្រី សម្រាប់កិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និង៤៥ និងកិច្ចប្រជុំពាក់ព័ន្ធ។

## ច. ការអនុវត្តកម្មវិធីជំនួយសង្គម

### ច.១. កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ

**ប.ស.ស.** បានផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក **ប.ស.ស.** ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដល់ម្តាយចំនួន ១២៤ ៨១២នាក់ និងកូនចំនួន ១២៣ ៦៦៣នាក់ ដោយចំណាយអស់ទឹកប្រាក់ ១០៦ ៤០១,៣៦លានរៀល។ បើគិតត្រឹមឆ្នាំ២០២៤ នេះ បានឧបត្ថម្ភទឹកប្រាក់ដល់កម្មករនិយោជិតជាស្ត្រីសម្រាលកូនចំនួន ៥៧៣ ៨៨៩នាក់ និងកូនចំនួន ៥៦២ ០៥៩នាក់ ដោយចំណាយអស់ទឹកប្រាក់ ២៩៦ ៥៦៦,៨៨លានរៀល។

**តារាងទី១៥៖ ការផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ**

| បរិយាយ | ឆ្នាំ2023 | ឆ្នាំ2024 | បម្រែបម្រួល (%) |
|---|---|---|---|
| ម្តាយ (នាក់) | 207,234 | 124,812 | -39.77% |
| កូន (នាក់) | 181,176 | 123,663 | -31.74% |
| ចំណាយ (លានរៀល) | 49,552.88 | 106,401.36 | 114.72% |

ប្រភព៖ នាយកដ្ឋានតាវកាលិកសន្តិសុខសង្គម (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី២ តារាង៦.១ ដល់តារាង៦.២)

**ក្រាហ្វិកទី១៣៖ ការផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ គិតចាប់ពីការអនុវត្ត**




ប្រភព៖ នាយកដ្ឋានតាវកាលិកសន្តិសុខសង្គម (ទិន្នន័យលម្អិតសូមមើលក្នុងឧបសម្ព័ន្ធទី២ តារាង៦.១ ដល់តារាង៦.២)

### ច.២. ការចុះបញ្ជី និងផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល

